# កម្រិតភស្តុតាង និង បន្ទុកនៃភស្តុតាង ក្នុងរឿងព្រហ្មទណ្ឌ

ដោយបណ្ឌិត មាស បូរ៉ា និង លោក វឌ្ឍា ពិសិដ្ឋ

## ១. សេចក្តីផ្តើម

ក្នុងការវិនិច្ឆ័យសេចក្តីណាមួយ ចៅក្រមសម្រេចដាក់ពន្ធនាគារ ផ្អែកលើ ភស្តុតាង។ ភស្តុតាងមានច្រើនប្រភេទ មានកម្រិត និងបន្ទុកនៃភស្តុតាង ដែលមេធាវី ចៅក្រម ត្រូវដឹង និងអនុវត្តតាម ដើម្បីឲ្យសេចក្តីសម្រេចខ្លួន សមស្រប និងប្រកបដោយយុត្តិធម៌។ ផ្អែកតាមភស្តុតាង ចៅក្រមអាចដាក់ទោស ពន្ធនាគារធ្ងន់ ឬស្រាល។ វានឹងមិនជាបញ្ហាធ្ងន់ធ្ងរទេ ប្រសិនបើ អ្នកប្រព្រឹត្តពិតជាបានប្រព្រឹត្ត។ ផ្ទុយទៅវិញ វានឹងមានគ្រោះ និងហានីភ័យខ្លាំង ប្រសិនបើ កាត់ទោសអ្នកមិនប្រព្រឹត្តបទឧក្រិដ្ឋខុស ដាក់ពន្ធនាគារ ដោយសារភស្តុតាងខុស។ សិទ្ធិបុគ្គលត្រូវបានរំលោភ ប្រយោជន៍របស់ពួកគេ ត្រូវបានបាត់បង់។ រដ្ឋនឹងសងជំងឺចិត្តជនរងគ្រោះ ក្នុងទឹកប្រាក់រាប់លាន ដុល្លារ ចំណាយលុយដាក់ពន្ធនាគារ អ្នកមិនមានទោស ដែលជាការឥតប្រយោជន៍ ថែមទាំងទទួលរងនូវការរិះគន់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយសារកំហុសរបស់ចៅក្រម។ កំហុសធម្មតា កើតពីការបកស្រាយច្បាប់ (no more legal error) ដែលគ្មានចេតនាទុច្ចរិត (malice) ចៅក្រមនឹងមិនទទួលខុសត្រូវទេ ដោយសារមានអភ័យឯកសិទ្ធិ។ ផ្ទុយទៅវិញ ប្រសិនមានកំហុស អាចទទួលរងពិន័យ ឬបញ្ឈប់ពីមុខងារចៅក្រមក្នុងករណីធ្ងន់ធ្ងរ ឬទទួលខុសត្រូវព្រហ្មទណ្ឌ។ ទាំងអស់នេះ វាពិតជាកើតមានរួចហើយ។

អ្នកនិពន្ធសង្កេតឃើញថា បញ្ហាភស្តុតាងជារឿងសំខាន់ និងស្មុគ្រស្មាញ មិនមានច្បាប់ចែងច្បាស់លាស់។ បន្ថែមពីលើនេះ មិនមានការសិក្សាស្រាវជ្រាវច្រើនទេ។ គោលបំណង នៃអត្ថបទនេះ ដើម្បីស្រាយបញ្ហានេះ ក្នុងវិសាលភាពក្តោបលើកម្រិត និងបន្ទុកនៃភស្តុតាង ក្នុងដំណើរការក្តីរឿងព្រហ្មទណ្ឌ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ អត្ថបទ នឹងបង្ហាញអំពីប្រភេទនៃកម្រិតភស្តុតាង បុគ្គលទទួលខុសត្រូវដាក់ភស្តុតាង ទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗ និង ថាតើនៅពេលណាដែលបន្ទុកនៃភស្តុតាងត្រូវបានផ្ទេរទៅភាគីម្ខាងទៀត?។ អ្នកនិពន្ធរំពឹងថា អត្ថបទនេះ នឹងចូលរួមចំណែកបំពេញបន្ថែម នូវចំណេះដឹងរបស់លោកមេធាវី ចៅក្រម និង ព្រះរាជអាជ្ញា ដែលមានស្រាប់។

## ២. កម្រិតនៃភស្តុតាង (Standard of Proof)

កម្រិតភស្តុតាងយ៉ាងតិចមានពីរប្រភេទទៅតាមប្រភេទនៃរឿង៖ ទី១. សមតុល្យនៃលទ្ធភាពដែលអាចកើតមាន (Balance of Probability or Preponderance of the Evidence ) សម្រាប់រឿងរដ្ឋប្បវេណី ឧទាហរណ៍ ជម្លោះរវាងបុគ្គលទាមទារកម្មសិទ្ធិលើដីជាដើម។[1] ទី២. ហួសពីវិមតិសង្ស័យ (Beyond Reasonable Doubt) ប្រើសម្រាប់ក្នុងរឿងព្រហ្មទណ្ឌ។ មាត្រា ៣២១ ចែងថា៖ *តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាង ដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន*[2]ជាឃ្លាបង្ហាញពីកម្រិតនៃភស្តុតាងនៃស៊ីវិលឡ ហើយដែលគេគិតថា មានកម្រិតស្រដៀងនឹងហួសពីវិមតិសង្ស័យ។ វាជាកម្រិតភស្តុតាង ដែលបង្កើតនូវពិរុទ្ធភាព ផ្អែកតាមការពិចារណាដោយអព្យាក្រឹត្យ (unprejudiced mind)។ វាមិនទាមទារនូវភាពច្បាស់លាស់ដាច់ខាតទេ តែគ្រាន់តែភាពច្បាស់លាស់ (moral certainty) បង្ហាញពីវត្តមាននៃធាតុផ្សំនៃបទល្មើស ព្រមទាំងអត្តសញ្ញាណនៃអ្នកប្រព្រឹត្ត។[3] ការទាមទារនូវកម្រិតភស្តុតាងខ្ពស់ដូចនេះ ដោយសារ ក្នុងករណីជាពិសេស *ជនត្រូវចោទ ត្រូវបានចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ មិនគ្រាន់តែបាត់បង់កិត្តិយសទេ ថែមទាំង សិទ្ធិសេរីភាព និងជីវិតផងក៏ថាបាន*។[4]

---

[1] *"To 'establish by a preponderance of the evidence' means to prove that something is more likely so than not so. In other words, a preponderance of the evidence in the case means such evidence as, when considered and compared with that opposed to it, has more convincing force, and produces in your minds belief that what is sought to be proved is more likely true than not true. This rule does not, of course, require proof to an absolute certainty, since proof to an absolute certainty is seldom possible in any case."* O'Malley K. F, Grenig J. E. and Lee W. C. (eds.), ការណែនាំ និង ការអនុវត្ត នៃអង្គវិនិច្ឆ័យសហព័ន្ធ, ២០០១, § 166.51, *see* as well, Mark Schweizer, កម្រិតភស្តុតាងក្នុងបណ្តឹងរដ្ឋប្បវេណី-តើការពិត វាជាអ្វី? ខែកក្កដា ឆ្នាំ ២០១៣ 2013, ទំ. ៤។. Dr. Mojtaba Kazazi, បន្ទុកនៃភស្តុតាង និងបញ្ហាពាក់ព័ន្ធ, ការសិក្សាអំពីភស្តុតាងមុខតុលាការអន្តរជាតិ ឆ្នាំ ១៩៩៦ ទំ.៣៨៤។

[2] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ ២០០៧។ It is inner conviction or *intime* conviction, *see* មគ្គទេសសម្រាប់ប្រៀបធៀបច្បាប់ជាអន្តរជាតិ, បទឧក្រិដ្ឋជំនួញនៃប្រទេសបារាំង, ឆ្នាំ ២០១៨ កថាខ័ណ្ឌ ៩២., https://iclg.com/practice-areas/business-crime-laws-and-regulations/france#chaptercontent9; conviction beyond reasonable doubt is based on a certainty means 'l'intime conviction porte sur une certitude', see http://context.reverso.net/translation/english-french/conviction+beyond+reasonable+doubt

[3] Albert Lee G. Angeles, ការដាក់ពិរុទ្ធភាពមិនត្រឹមត្រូវ និង ករណីភស្តុតាងបែបវិទ្យាសាស្រ្ត ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រទេសហ្វីលីពីន, 57 Ateneo Law Journal, ឆ្នាំ ២០១៣, ទំ. ១១៦៧។

[4] *People v. Dilamanta*, 440 SCRA 55,56 (2004).

បន្ថែមពីលើនេះ ក្នុងរឿងប្រភេទណាមួយ ដូចជាព្រហ្មទណ្ឌកម្រិតនៃភស្តុតាង កម្រិតនៃភស្តុតាងទាបឬខ្ពស់ អាស្រ័យទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗ។ សម្រាប់ការឃាត់ខ្លួនបុគ្គលណាមួយដើម្បីសាកសួរ ដោយសង្ស័យថា អាចនឹងប្រព្រឹត្តបទល្មើសណាមួយ កម្រិតនៃភស្តុតាងគឺ ការសង្ស័យដែលមានហេតុផល (Reasonable Suspicion)។ ក្នុងអំឡុងពេលល្បាត ប៉ូលីសបានពិនិត្យឃើញបុគ្គលម្នាក់នៅទីងងឹត មុខរបងផ្ទះគេ មានកន្ត្រៃកាត់ដែក។ នេះអាចជាករណីសង្ស័យដែលមានហេតុផល។ ដើម្បីបើកការស៊ើបអង្កេតបឋមបាន សហព្រះរាជអាជ្ញាគ្រាន់តែមានហេតុផលឲ្យជឿថា បុគ្គលណាមួយបានប្រព្រឹត្តបទល្មើស។[5] ក្នុងអំឡុងពេលនៃការស៊ើបអង្កេតដោយចៅក្រមស៊ើបសួរ ក្នុងការដាក់ជនសង្ស័យណាម្នាក់ក្រោមការស៊ើបអង្កេត[6](Notification of Charge) ចៅក្រមស៊ើបអង្កេតត្រូវបង្ហាញភស្តុតាងត្រឹមកម្រិត ច្បាស់លាស់និងស៊ីសង្វាក់ (Coherent and Consistent Evidence)។[7] ការឃុំខ្លួនបណ្តោះអាសន្នតម្រូវ ឲ្យមានហេតុផលជឿថា (reason to believe) ជននោះ បានប្រព្រឹត្តបទល្មើស។[8] ក្រោយបិទបញ្ចប់ការស៊ើបអង្កេត ចៅក្រមស៊ើបអង្កេត ចោទប្រកាន់ (Indictment) ដើម្បីបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះ ចៅក្រម ត្រូវបង្ហាញថាមានភស្តុតាងគ្រប់គ្រាន់ (Sufficient

---

[5] វិធាន ៥៣ នៃវិធានផ្ទៃក្នុងរបស់ អវតក។ ការសង្ស័យដោយមានហេតុផល ជាការសន្មត់ ដែលនាំឲ្យប៉ូលីសជឿ តាមការសិក្សា ថាបទល្មើសកើតមាន។ វាហួសពីការគ្រាន់តែស្មាន ក៏ប៉ុន្តែ ទាបជាង Probable Cause ដែលជាជំនឿពិតមួយ (logical believe) ផ្អែកតាមអង្គហេតុ និងស្ថានភាព ថា បទល្មើស អាចកំពុងត្រូវបានប្រព្រឹត្ត, https://www.taylorlawco.com/blog/reasonable-suspicion-and-probable-cause-what-s-the-difference.cfm.

[6] ចៅក្រមស៊ើបអង្កេត កោះហៅឲ្យជនសង្ស័យចូលខ្លួន (Initial Appearance) ហើយជូនដំណឹងអំពីការ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ (មាត្រា ១៤៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧)។ ចាប់ពីពេលនោះមកដាក់បុគ្គលក្រោមការស៊ើបអង្កេត ហើយជនសង្ស័យក្លាយជាជនត្រូវចោទ ដែលអាចចូលមើលសំណុំរឿង និងមានសិទ្ធិជាច្រើនបន្ថែមទៀត ដូចជា សិទ្ធិមានមេធាវីជាដើម។

[7] មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

[8] បន្ថែមពីលើភាពចាំបាច់នៃការឃុំខ្លួន, អវតក, វិធាន ៥៣ (៣) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ជាពិសេសមាត្រា ២០៥ មិនបានចែងអំពីកម្រិតនៃភស្តុតាង សម្រាប់សម្រេចឃុំខ្លួនបណ្តោះអាសន្នទេ គ្រាន់តែចែងថា ការឃុំខ្លួនត្រូវតែជាការចាំបាច់។

Evidence) ថាជនត្រូវចោទ (Charged Person) បានប្រព្រឹត្តបទល្មើស។[9] ជាចុងក្រោយ ក្នុងអំឡុងសវនាការ ព្រះរាជអាជ្ញា ប្រសិនបើចង់ឲ្យចៅក្រមជំនុំជម្រះ រកឃើញថាជនជាប់ចោទ មានពិរុទ្ធភាព (Guilt Person) គាត់ត្រូវបង្ហាញភស្តុតាងដល់កម្រិតហួសពីវិមតិសង្ស័យដូចខាងលើ។[10]

តាមការបង្ហាញខាងលើ ក្នុងរឿងព្រហ្មទណ្ឌ កម្រិតនៃភស្តុតាងយ៉ាងតិចមានបួនកម្រិត មានពីទាបទៅខ្ពស់។ ការទាមទារដូចនេះ ពិតជាមានហេតុផលដោយសារ ចាប់តាំងពីការផ្តើមនៃនីតិវិធី (ឃាត់ខ្លួន) អាជ្ញាធរមានសមត្ថកិច្ច អាចមានតែភស្តុតាងតិចតួច ឬតែមួយ ហើយក្រោយពីធ្វើការស៊ើបអង្កេតមួយរយៈមក អាជ្ញាធរ ប្រមូលភស្តុតាងបានកាន់តែច្រើន ដែលអាចយកមកពិនិត្យជារួម ដើម្បីរកឃើញថា ភស្តុតាងទាំងអស់ស៊ីសង្វាក់គ្នាឬមិនស៊ីសង្វាក់គ្នាយ៉ាងណា។ បន្ថែមពីលើនេះ ពីមួយដំណាក់កាលនីតិវិធីទៅមួយដំណាក់កាលទៀត លទ្ធផលនៃការស៊ើបអង្កេតកាន់តែស្តែងជាក់លាក់ថាតើបុគ្គលណាមួយ បានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបទល្មើស ដែលត្រូវបានចោទ។ ប្រសិនបើរកមិនឃើញទេ ជនត្រូវចោទអាចនឹងត្រូវបានលើកលែងចោទប្រកាន់។ ដំណាក់កាលនីមួយៗ ត្រូវបានកំណត់ក្នុងរយៈពេលជាក់លាក់ ហើយការស៊ើបអង្កេត ត្រូវបានទាមទារឲ្យឆាប់រហ័ស ជាពិសេសក្នុងករណីដែលជនសង្ស័យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដោយសារវាពាក់ព័ន្ធនឹងការដកហូតនូវសិទ្ធិសេរីភាព។ ក្នុងន័យនេះ ប្រសិនបើការស៊ើបអង្កេត មិនមានភាពជឿលឿន ចំណាយពេលវេលាយូរ ភស្តុតាងដែលប្រមូលបាន មិនគ្រប់គ្រាន់ ហើយជនត្រូវចោទនៅតែត្រូវបានបញ្ជូនទៅជំនុំជម្រះ នីតិវិធីដែលពាក់ព័ន្ធអាចមានវិការៈ (Defect) ឬការបំពារបំពាន ដែលអាចជាកម្មវត្ថុនៃការសុំមោឃៈភាព។

---

[9] នៅក្នុងដំណាក់កាលនេះ ប្រសិនបើសហចៅក្រមសម្រេចបញ្ជូនទៅជំនុំជម្រះ ជនត្រូវចោទ ត្រូវបានប្តូរទៅជាជនជាប់ចោទ (Accused), *see* glossary annexed to the ECCC Internal Rules, https://www.eccc.gov.kh/.../ECCC%20Internal%20Rules%20%28Rev.8%29%20Englis..។មាត្រា ២៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧។

[10] Joshua Dressler, Understanding Criminal Law, 5th Ed., 2009, p. 68; Cross Jones and Card, Introduction to Criminal Law, 11th Ed.,1988, pp. 103-104; standard of proof “beyond reasonable doubt” reflect absolute certainty, International Comparative Law Guide, Business Crime, Germany, 2018, para. 9.2, https://iclg.com/practice-areas/business-crime-laws-and-regulations/germany; Lissa Griffin, *the Correction of Wrongful Convictions: A Comparative Perspective*, 16 Am. U. Int’l L. Rev., 2001, p. 1272.

មូលហេតុអាចត្រូវបានទាមទារឲ្យបង្ហាញថាតើហេតុអ្វីក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ទាមទារឲ្យមាន កម្រិតភស្តុតាងខ្ពស់ម្ល៉េះ? រឿងព្រហ្មទណ្ឌ អាចនាំឲ្យមានការកាត់ទោសដាក់ពន្ធនាគារ[11] ដកហូតសិទ្ធិសេរីភាព ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់បុគ្គល ឬអាចនាំឲ្យមានការចោទប្រកាន់ថា រដ្ឋរំលោភនូវកាតព្វកិច្ច ក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលខ្លួនជាភាគី ដោយសារអំពើរបស់មន្ត្រីរបស់ខ្លួន ដែលដកហូតនូវសិទ្ធិសេរីភាព។[12]

**៣. បន្ទុកនៃភស្តុតាង** (Burden of Proof)

ក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាជាមន្ត្រីទទួលបន្ទុកប្រមូលភស្តុតាងដាក់បន្ទុក (Inculpatory Evidence)[13] រកឲ្យឃើញថា បុគ្គលដែលខ្លួនបានចោទប្រកាន់បានប្រព្រឹត្តបទល្មើស។ ហេតុអ្វី? តើជនសង្ស័យមានកាតព្វកិច្ចដាក់ភស្តុតាងឬទេ? តើព្រះរាជអាជ្ញាត្រូវបង្ហាញត្រឹមវិសាលភាពកម្រិតណា?

គោលការណ៍សន្មត់ទុកជាមុនថាគ្មានទោស (Presumption of Innocence) ដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ "*ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់*

---

[11] ពាក់ព័ន្ធនឹងចំណុចនេះ ច្បាប់រដ្ឋធម្មនុញ្ញ ចែងអំពីគោលការណ៍សន្មត់ទុកជាមុនថាមិនទាន់មានទោស និងវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ហើយ ការទទួលសារភាពដែលកើតឡើងពី ការបង្ខិតបង្ខំ...មិនត្រូវចាត់ទុកជាភស្តុតាងទេ(មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣)។ ការបកស្រាយច្បាប់ព្រហ្មទណ្ឌទាមទារឲ្យមានលក្ខណៈតឹងរឹង (មាត្រា៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩)។ ជាគោលការណ៍ ជនត្រូវចោទមានសេរីភាព ឃុំខ្លួនជាបណ្ដោះអាសន្ន ក្នុងតែករណីចាំបាច់ (មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧)។

[12] The United Nation Human Rights Committee General Comment No.31 on the Nature of the General Obligation Imposed on States Parties to the Covenant Adopted on 29 March 2004, para. 4.

[13] កំណែទម្រង់ច្បាប់ព្រហ្មទណ្ឌនៃប្រទេសខ្លះ បានកំណត់ថា ព្រះរាជអាជ្ញា លែងជាភាគីតំណាងឲ្យរដ្ឋនៃសំណុំរឿងព្រហ្មទណ្ឌហើយ។ ស្ថាប័នអយ្យការ កាន់តែមានឯករាជ្យភាពច្រើនពីនីតិប្រតិបត្តិ។ គាត់ជាភាគី អព្យាក្រឹត្យ ដែលត្រូវប្រមូលទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក (Exculpatory Evidence)។ កំណែទម្រង់នៅប្រទេសបារាំងបានបង្ហាញថា រដ្ឋអាជ្ញាទទួលយកការងាររបស់ចៅក្រមស៊ើបសួរកាន់តែច្រើន និងមានឯករាជ្យភាពកាន់តែច្រើនពីអំណាចនីតិប្រតិបត្តិ។ គាត់ជាភាគីអព្យាក្រឹត្យ, Jacqueline Hodgson, *Guilty Pleas and the Changing Role of the Prosecutor in French Criminal Justice*, in Erik Luna and Marianne L. Wade, the Prosecutor in Transnational Perspective, 2012, p.133 ។ គាត់មានកាតព្វកិច្ច បញ្ចេញនូវភស្តុតាង (Disclosure) ដោះបន្ទុកដល់ជនសង្ស័យផងដែរ។ Guideline 15 of the UN impartiality of prosecutor, Lisa M. Kurcias, *Prosecutor's Duty to Disclose Exculpatory Evidence*, 69 Fordham L. Rev. 1205 (2000); ICLGG, Germany, 2018, para. 9.1, *supra* note 10.

*កាត់ទោសជាស្ថាពរ*[14] បានតម្រូវថា ព្រះរាជអាជ្ញាជាអ្នកមានបន្ទុកបង្ហាញភស្តុតាង។ ការតម្រូវឲ្យបុគ្គលបង្ហាញភស្តុតាងដោះសារថា គាត់មិនបានប្រព្រឹត្ត នឹងមិនស៊ីគ្នានឹងគោលការណ៍នេះទេ។ ការបង្ហាញដោយជនត្រូវចោទថា បានប្រព្រឹត្តបទល្មើស (Self-Incrimination) ដូចជាតាមរយៈការឆ្លើយសារភាពដោយបង្ខំ ក៏នឹងផ្ទុយនឹងគោលការណ៍នេះផងដែរ។[15] ពាក់ព័ន្ធនឹងចំណុចនេះហើយ ដែលច្បាប់បានចែងឲ្យបុគ្គលមានសិទ្ធិរក្សាភាពស្ងៀមស្ងាត់ (Right to Silent)។[16]

ការបង្ហាញភស្តុតាងអាចដើម្បីធ្វើឲ្យគេជឿ (Persuasive Proof) ឬការគ្រាន់តែបង្ហាញភស្តុតាង (Evidence Proof) ឬការបង្ហាញភស្តុតាងដោះសារ (Defence)។ ព្រះរាជអាជ្ញា មិនគ្រាន់បង្ហាញភស្តុតាងប៉ុណ្ណោះទេ តែត្រូវបង្ហាញឲ្យចៅក្រមជឿ (Persuasive)។[17] ការអះអាងនេះ ហាក់បង្ហាញថា ភាគីទាំងពីរមានបន្ទុកនៃភស្តុតាងខុសគ្នា ដែលអាចផ្ទុយនឹងគោលការណ៍សមភាពនៃភាគី (Equality of Arms)។[18] ការពិតវាមិនខុសនឹងគោលការណ៍នេះទេ។ ការដាក់បន្ទុកស្រាលដល់ជនត្រូវចោទនេះដោយសារថា បុគ្គលខុសពីស្ថាប័នព្រះរាជអាជ្ញា ដែលមានបុគ្គលិកច្រើន មានអំណាច និងយន្តការក្នុងការប្រមូលភស្តុតាង។ អាស្រ័យហេតុនេះ ជនត្រូវចោទគ្រាន់តែបង្ហាញភស្តុតាងការពារខ្លួនតែប៉ុណ្ណោះ។

---

[14] មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣។

[15] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ ECCC, Supreme Court Chamber, Decision on Objections to Document Lists (Full Reasons), F26/12, 31 December 2015។ Dr. Mojtaba Kazazi, Burden of Proof and Related Issues, A Study Evidence before International Tribunals, 1996, p. 16.

[16] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៤៣ តម្រូវឲ្យប្រាប់សិទ្ធិមិននិយាយ សិទ្ធិមានមេធាវី។ ក្នុងសហរដ្ឋអាមេរិក ប៉ូលីសតម្រូវឲ្យប្រាប់ជនសង្ស័យថា សក្ខីកម្ម របស់គាត់នឹងត្រូវបានប្រើក្នុងនីតិវិធីនាពេលខាងមុខ ហើយ ជនសង្ស័យមានសិទ្ធិឆ្លើយឬមិន។ ការខកខានមិនបានប្រាប់ នឹងនាំឲ្យសក្ខីកម្មនេះ ត្រូវបានបិដសេធនាពេលខាងមុខ (Miranda Warning), *Miranda v. Arizona* [(Miranda, 384 US 436 (1966)]។ ចៅក្រមមិនអាចទាញការសន្និដ្ឋាន ពីភាពស្ងៀមស្ងាត់របស់ជនត្រូវចោទទេ, Stephen C. Thaman, Exclusionary Rules in Comparative Law (France), 2013, p. 156.

[17] Joshua Dressler, *supra* note 10, p. 70.

[18] "*Each part must afforded a reasonable opportunity to present his case in conditions that do not place him at a disadvantage vis-a-vis his opponent*", ECtHR, *Bulut v. Austria*, App. No. 17358/90, Judgment of 22 February 1996, para. 47; Masha Fedorova, the Principle of Equality of Arms in International Criminal Proceedings, 2012, p.38.

នៅពេលព្រះរាជអាជ្ញាបំពេញបានបន្ទុករបស់ខ្លួនហើយ បន្ទុកនៃភស្តុតាងនឹងត្រូវបានផ្ទេរទៅជនត្រូវចោទវិញ។[19] ទោះបីជាយ៉ាងនេះក្តី ដើម្បីកុំឲ្យផ្ទុយនឹងគោលការណ៍ សន្មត់ទុកជាមុនថាគ្មានទោស ជនត្រូវចោទ *មិនតម្រូវឲ្យបង្ហាញភស្តុតាងថាខ្លួនមិនបានប្រព្រឹត្តបទល្មើសទេ* គឺបង្ហាញភស្តុតាងគាំទ្រការដោះសារ (Justification/Excuse) ដូចជាថា អំពើរបស់ខ្លួនជាទង្វើការពារខ្លួនស្របច្បាប់ (Self-Defence)។[20] ជនត្រូវចោទ ត្រូវបង្ហាញត្រឹមកម្រិតភស្តុតាង Balance of Probability ដែលមានន័យថា ៥០% បូកមួយ ដែលវាជាការការពារខ្លួនដោយស្របច្បាប់ប្រាកដមែន។[21] មានការអះអាងថាការទាមទារឲ្យបង្ហាញការការពារថា ជនសង្ស័យ មិនបាននៅកន្លែងកើតហេតុ (*alibi*) នាពេលបទល្មើសត្រូវបានប្រព្រឹត្ត ថាដូចជាការបង្ហាញថាមិនបានប្រព្រឹត្តបទល្មើស ដែលផ្ទុយនឹងគោលការណ៍សន្មត់ទុកជាមុន។ វាមិនខុសទេ ដោយសារថា បន្ទុកភស្តុតាងធ្លាក់លើភាគីដែលជាអ្នកប្តឹង។[22] តាមការពិត ការបង្ហាញដោយជនត្រូវចោទ គឺបង្ហាញផ្សេង ប្រើភស្តុតាងផ្សេង ដូចជាថា មានសាក្សីអះអាងថាជនត្រូវចោទនៅទីកន្លែងផ្សេង ពីកន្លែងកើតហេតុនៃពេលបទល្មើសកំពុងត្រូវបានប្រព្រឹត្ត។ ច្បាប់មិនតម្រូវឲ្យជនជាប់ចោទ បង្ហាញធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវទេ។ ទាំងនេះជាបន្ទុករបស់ព្រះរាជអាជ្ញា ដែលជាអ្នកបង្ហាញ។ ពាក់ព័ន្ធបន្ទុកនៃភស្តុតាង ជនជាប់ចោទមានកាតព្វកិច្ចក្នុងការផ្តល់ភស្តុតាង គាំទ្រអង្គហេតុដែលខ្លួនចង់នៅក្រៅឃុំ ដោយដាក់ប្រាក់ធានា[23] ស្ថានសម្រាលទោស[24] និងសេចក្តីថ្លែងការណ៍ដែលខ្លួនបានចោទថាត្រូវបានធ្វើឡើងដោយមិនស្ម័គ្រចិត្ត។[25]

ក្នុងន័យនេះ ការណ៍ដែលថៅក្រមតម្រូវឲ្យ ជនជាប់ចោទដាក់ភស្តុតាងដោះបន្ទុក អាចមិនជាការត្រឹមត្រូវទេ។ ដូចគ្នានេះដែរ ការណ៍ដែលមេធាវីរបស់ជនជាប់ចោទទទួលស្គាល់ថា ខ្លួនជាអ្នករកភស្តុតាងដោះបន្ទុក ក៏មិនមែនជាការត្រឹមត្រូវដែរ។ ក្រៅពីគ្មានមូលដ្ឋានក្នុងច្បាប់ វាមិនអាចទៅរួចទេ

---

[19] International Comparative Law Guide, Business Crime, Australia, 2018, para. 9.1, https://iclg.com/practice-areas/business-crime-laws-and-regulations/australia.

[20] *Id*., para. 11.2.

[21] Ben Emmerson and Andrew Ashworth, Human Rights and Criminal Justice, 2 ed., 2007, p. 346; Goran Sluiter, Proof, in Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p. 469.

[22] Dr. Mojtaba Kazazi, Burden of Proof and Related Issues, *supra* note 15, p. 2.

[23] Sentence of Death or Life Imprisonment, Aggravating and Mitigating Circumstances; Definition, *see* https://www.azleg.gov/ars/13/00751.htm

[24] Doug Keller, *Resolving A "Substantial Question": Just Who Is Entitled to Bail Pending Appeal under the Bail Reform Act of 1984*, 60 Florida Law Review, 2008, p. 827.

[25] Goran Sluiter, Proof (Burden of), *supra* note 21, p. 468-469.

ដោយពិចារណាលើលទ្ធភាពរបស់មេធាវី ជាពិសេស មេធាវីក្នុងប្រទេស ស៊ីវិលឡូ ដែលការស៊ើប អង្កេតមុនជំនុំជម្រះ ជាសម្ងាត់ ធ្វើឡើងដោយចៅក្រមស៊ើបអង្កេត[26] និងមានការចូលរួមតិចតួចបំផុត របស់មេធាវី។ មេធាវី បានត្រឹមតែយកភស្តុតាងក្នុងសំណុំរឿង មកតទល់នឹងភស្តុតាងដាក់បន្ទុករបស់ ព្រះរាជអាជ្ញា។ បន្ថែមពីនេះ មេធាវីអាច សួរតទល់ (Cross-Examination) នឹងសាក្សីដាក់បន្ទុក[27] ដើម្បីបង្ហាញថាការចោទប្រកាន់របស់ព្រះរាជអាជ្ញាមិនត្រឹមត្រូវ នៅក្នុងអំឡុងពេលសវនា ដែលនីតិវិធី នៅមានកម្រិតនៅឡើយ។

**៤. ការបង្ហាញភស្តុតាង**

ព្រះរាជអាជ្ញា ត្រូវបង្ហាញថា ជនត្រូវចោទបានប្រព្រឹត្តបទល្មើសក្នុងទម្រង់ជាក់លាក់ណាមួយ ដូចជា បានញុះញង់ នាំឲ្យមានបទល្មើសជាដើម។ ឧទាហរណ៍ សម្រាប់បទល្មើស មនុស្សឃាតដោយ ចេតនា ព្រះរាជអាជ្ញាត្រូវបង្ហាញ ថា៖ ១. បទល្មើសនេះមានចែងក្នុងច្បាប់ (Legal Element)។ ២. ជនជាប់ចោទបានប្រើកាំភ្លើងបាញ់ជនរងគ្រោះបណ្តាលឲ្យស្លាប់ (ធាតុផ្សំនៃអំពើ) និងទី៣. ជនជាប់ ចោទមានចេតនាធ្វើឲ្យជនរងគ្រោះស្លាប់ (ធាតុផ្សំអត្តនោម័ត)។[28] បន្ថែមពីលើនេះ ច្បាប់ក៏តម្រូវឲ្យព្រះ រាជអាជ្ញាបង្ហាញនូវទម្រង់ទទួលខុសត្រូវ ព្រមទាំងធាតុផ្សំនៃទម្រង់ទទួលខុសត្រូវផងដែរ។[29] ជាក់ ស្តែង សហព្រះរាជអាជ្ញា ត្រូវបង្ហាញថា ទម្រង់ទទួលខុសត្រូវសហឧក្រិដ្ឋរួម ត្រូវបានចែងក្នុងច្បាប់ ឬក្រោមវិធានទំនៀមទម្លាប់អន្តរជាតិ ប្រសិនបើចង់អនុវត្តទម្រង់នេះសម្រាប់ជនជាប់ចោទ។[30] អង្គ ជំនុំជម្រះ យល់ឃើញថា ហួសពីវិមតិសង្ស័យថា ជនជាប់ចោទ ទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងឋានៈ ជាអ្នកប្រព្រឹត្តការបណ្តេញចេញ។[31] តុលាការជាន់ខ្ពស់របស់ស៊ីង្ហបុរីបានអះអាងថា៖ *ជាសង្ខេប សម្រាប់បទល្មើស ក្នុងផ្នែក ៥(ក) (ជួយល្បែងភ្នាល់ខុសច្បាប់ ធាតុផ្សំចំនួនពីរត្រូវតែបង្ហាញ ហួស*

---

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ ២០០៧, មាត្រា ៨៣។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ ២០០៧, មាត្រា ១៣៣។

[28] ICLG, France, *supra* note 2, para. 9.2.

[29] *See, e.g.*, *Stakić* Appeal Judgement, para. 219 ("A Trial Chamber may only find an accused guilty of a crime if the Prosecution has proved each element of that crime (as defined with respect to the relevant mode of liability) beyond a reasonable doubt."); *Ntagerura et al.* Appeal Judgement, para. 174.

[30] Case 002, IENG Sary's Motion against the Application at the ECCC of the Form of Liability Known as Joint Criminal Enterprise, D97, 28 July 2008, para. 29.

[31] ICTY, TC, *Simic et al.*, IT-95-9, Oct 17, 2003, paras. 1051-1053.

*ពីវិមតិសង្ស័យ។ទី១.ជនត្រូវចោទត្រូវមានគោល<u>បំណងជួយអ្នក</u>គ្រប់គ្រងល្បែងភ្នាល់ខុសច្បាប់..។ ទី២. ជនត្រូវចោទត្រូវធ្វើអំពើជាចំហរជួយសកម្មភាពឆ្នោតសាធារណៈ។*[32] តាមទ្រឹស្តីភស្តុតាង ភស្តុតាងគួរតែមានគ្រប់គ្រាន់ ប្រមូលបានក្នុងអំឡុងពេលស៊ើបអង្កេតដ៏សមស្រប និង ពេញលេញមួយ ហើយពិចារណាជារួម (Robust Evidence) សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តណាមួយ។

តើអ្វីជាការបង្ហាញហួសពីវិមតិសង្ស័យ? ព្រះរាជអាជ្ញាត្រូវព្យាយាមជំម្រះ គ្រប់ភស្តុតាងសំខាន់ *ពាក់ព័ន្ធការប្រព្រឹត្តិបទល្មើស និង ទម្រង់ដែលបុគ្គលចូលរួម* ដែលនាំឲ្យមានការសង្ស័យថា ជនជាប់ចោទមិនបានប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ក្នុងរឿងសម្លាប់មនុស្ស ភស្តុតាងសំខាន់ អាចជាកាំភ្លើង និងអាវប្រឡាក់ឈាម។ ព្រះរាជអាជ្ញាត្រូវជម្រះ មន្ទិលថាតើកាំភ្លើងជារបស់ជនជាប់ចោទ ជនជាប់ចោទជាអ្នកបាញ់កាំភ្លើង និង ឈាមដែលប្រឡាក់អាវ ជាឈាមរបស់ជនរងគ្រោះ ហើយអាវដែលប្រឡាក់ឈាមជារបស់ជនជាប់ចោទ។ លុះត្រាតែព្រះរាជអាជ្ញា ជម្រះមន្ទិលស្ទើរតែទាំងអស់ដែលដោះបន្ទុកលើជនជាប់ចោទ ហើយរកឃើញថា មានភាគរយខ្ពស់ (៩០ ភាគរយ) ដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើស ទើបចៅក្រមសម្រេចដាក់ទោសជនជាប់ចោទ។

ការមិនបានគោរពតាមកម្រិតនៃភស្តុតាង នាំឲ្យមានការសម្រេចសេចក្តីមួយដែល សំអាងហេតុមិនគ្រប់គ្រាន់ នាំឲ្យមានសេចក្តីសម្រេចខុស។ វាអាចមកពីច្បាប់អនុវត្តខុស ឬបកស្រាយមិនត្រឹមត្រូវ។ វាអាចជា កំហុសធម្មតា កើតពីការបកស្រាយច្បាប់ (mere legal error) ដែលគ្មានចេតនាទុច្ចរិត (malice) ដែលចៅក្រមនឹងមិនទទួលខុសត្រូវទេ ដោយសារមានអភ័យឯកសិទ្ធិ។ ផ្ទុយទៅវិញ ប្រសិនបើមានកំហុស ចៅក្រមអាចទទួលរងពិន័យ ឬបញ្ឈប់ពីមុខងារចៅក្រមក្នុងករណីធ្ងន់ធ្ងរ ឬទទួលខុសត្រូវព្រហ្មទណ្ឌ។[33]

---

[32] Bijabahadur, 2017 SGHC 161, 10 July 2017, para. 55.
[33] Tbilisi, Analysis of the Judicial Liability System (National Legislation, International Standards and Local Practices), 2014, pp. 86-87.

## ៥. សង្ខេប

លទ្ធផលនៃការសិក្សាខាងលើ បានបង្ហាញថា មានកម្រិតភស្តុតាងជាច្រើន ក្នុងរឿងព្រហ្មទណ្ឌ និង បន្ទុកនៃភស្តុតាង ដែលត្រូវទទួលដោយភាគីទាំងអស់ក្នុងសំណុំរឿង។ កម្រិតភស្តុតាងទាមទារ ពីដំណាក់កាលនីតិវិធីមួយ ទៅមួយទៀត កាន់តែខ្ពស់ តម្រូវឲ្យមាននូវកំណើនចំនួននៃភស្តុតាងក៏ដូចជាភាពជាក់លាក់ ដើម្បីចង្អុលឲ្យឃើញថា អង្គហេតុអ្វីមួយ ជាអ្វីឲ្យប្រាកដជាក់លាក់។ បន្ថែមពីលើនេះ កម្រិតភស្តុតាងអ្វី វាអាស្រ័យទៅលើ កម្រិតនៃហានីភ័យ លើសិទ្ធិ និងផលប្រយោជន៍របស់ភាគី។ កម្រិតភស្តុតាង នេះវាពាក់ព័ន្ធផងដែរ នឹងបន្ទុកភស្តុតាង។ ជាក់ស្តែង ច្បាប់មិនតម្រូវឲ្យជនត្រូវចោទ ដើរតួសកម្មរកភស្តុតាង គ្រប់ប្រភេទទេ ដោយសារលទ្ធផល និងសមត្ថភាពរបស់បុគ្គលដែលមាន ប្រសិនបើធៀបនឹងអាជ្ញាធរសាធារណៈ។ ក្នុងន័យនេះ ហើយទើបបានជារដ្ឋអាជ្ញា នៅតែជាភាគីចំបង មានបន្ទុកធ្ងន់ ក្នុងការផ្តល់ភស្តុតាង។

ក្នុងវិស័យវិទ្យាសាស្ត្រសង្គម ឬសូម្បីវិស័យវិទ្យាសាស្ត្រពិត ក៏មិនអាចមានសុក្រឹត្យភាព ១០០ ភាគរយទេ។ អាស្រ័យហេតុនេះ កម្រិតភស្តុតាង និងបន្ទុកភស្តុតាង ព្រមទាំងការបង្ហាញជាក់ស្តែង ពិតជាមិនអាចរួចផុតពីភាពឆកល្វែងទេ។ ក៏ប៉ុន្តែ ប្រសិនបើភាគី ជាពិសេស អាជ្ញាធរទទួលបន្ទុក និងមានសមត្ថកិច្ច អនុវត្តតាមបានជាអតិបរមា ដើម្បីធានានូវយុត្តិធម៌ក្នុងសង្គមដោយគ្មានការរើសអើង។